# របាយការណ៍បច្ចេកទេសស្តីពី
# ស្ថិតិសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា


រៀបចំដោយ

**លេខាធិការដ្ឋានសហគ្រាសធុនតូចនិងមធ្យម**

**និង**

**ក្រុមការងារស្ថិតិសហគ្រាសធុនតូចនិងមធ្យម**

**ក្នុងនាម**

**អនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម**



**ខែ វិច្ឆិកា ឆ្នាំ ២០០៧**

# មាតិកា

បញ្ជីពាក្យបំព្រួញ និង អក្សរកាត់

១. សេចក្ដីផ្ដើម

២. សាវតានៃក្រុមការងារ គោលបំណង និង វិធីសាស្ត្រ

ក. សាវតា

ខ. គោលបំណង និង វិសាលភាព

គ. វិធីសាស្ត្រ

៣. បញ្ហាគន្លឹះអំពីស្ថិតិសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា

ក. បញ្ហា និង ចំណុចខ្វះខាត

ខ. ការអនុវត្តដោយប្រើទិន្នន័យរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល តំណាងឱ្យ SME នៅកម្ពុជានាពេលបច្ចុប្បន្ន

៤. ស្ថិតិសហគ្រាសធុនតូចនិងមធ្យមតាមក្រសួងនីមួយៗ

ក. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ខ. ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

គ. ក្រសួងទេសចរណ៍

ឃ. ក្រសួងពាណិជ្ជកម្ម

ង. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ច. ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

ឆ. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ជ. ស្ថិតិបន្ថែម

៥. អនុសាសន៍ស្ដីពីជម្រើសសម្រាប់ការប្រមូលស្ថិតិសហគ្រាសធុនតូចនិងមធ្យម នាពេលអនាគត

## ឯកសារពិគ្រោះ និង ឯកសារផ្សេងទៀត

ឧបសម្ព័ន្ធទី ១ : ប្រកាសស្តីពីការបង្កើតក្រុមការងារស្ថិតិសហគ្រាសធុនតូចនិងមធ្យម

ឧបសម្ព័ន្ធទី ២ : លេខកូដស្តង់ដារឧស្សាហកម្មអន្តរជាតិ — កែប្រែលើកទី ២ (ISIC Rev.2)

ឧបសម្ព័ន្ធទី ៣ : មូលដ្ឋានទិន្នន័យថ្នាក់ភូមិ និង ឃុំ-សង្កាត់ ឆ្នាំ ២០០៦

ឧបសម្ព័ន្ធទី ៤ : ទម្រង់គំរូនៃស្ថិតិ SME

ឧបសម្ព័ន្ធទី ៥ : លេខកូដស្តង់ដារអន្តរជាតិ — កែប្រែលើកទី ៤ (ISIC Rev. 4)

ឧបសម្ព័ន្ធទី ៦ : ស្ថិតិ SME ពីនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឧបសម្ព័ន្ធទី ៧ : ស្ថិតិ SME ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ឧបសម្ព័ន្ធទី ៨ : ស្ថិតិ SME ពីក្រសួងទេសចរណ៍

ឧបសម្ព័ន្ធទី ៩ : ស្ថិតិ SME ពីក្រសួងពាណិជ្ជកម្ម

ឧបសម្ព័ន្ធទី ១០ : ស្ថិតិ SME ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឧបសម្ព័ន្ធទី ១១ : ស្ថិតិ SME ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

ឧបសម្ព័ន្ធទី ១២ : ស្ថិតិ SME ពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

# បញ្ជីពាក្យបំព្រួញ និង អក្សរកាត់

| | | |
|---|---|---|
| FRT | Financial Reporting Template | គំរូរបាយការណ៍ហិរញ្ញវត្ថុ |
| ICT | Information Communication Technology | បច្ចេកវិទ្យា ពត៌មាន និងទូរគមនាគមន៍ |
| IMF | International Monetary Fund | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| ISIC | International Standard Industrial Classification | លេខកូដស្តង់ដារឧស្សាហកម្មអន្តរជាតិ |
| JICA | Japan International Cooperation Agency | ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| KHR | Khmer Riel (also known as Cambodian Riels) | រៀល |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ |
| MIME | Ministry of Industry, Mines and Energy | ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល |
| MLVT | Ministry of Labor and Vocational Training | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoC | Ministry of Commerce | ក្រសួងពាណិជ្ជកម្ម |
| MoP | Ministry of Planning | ក្រសួងផែនការ |
| MoT | Ministry of Tourism | ក្រសួងទេសចរណ៍ |
| MoWA | Ministry of Women's Affairs | ក្រសួងកិច្ចការនារី |
| MPTC | Ministry of Posts and Telecommunications | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| NAC | National Accounting Council | ក្រុមប្រឹក្សាជាតិគណនេយ្យ |
| NIS | National Institute of Statistics | វិទ្យាស្ថានជាតិស្ថិតិ |

| | | |
|---|---|---|
| NSDP | National Strategic Development Plan | ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ |
| PPTA | Project Preparatory Technical Assistance | ជំនួយបច្ចេកទេសរៀបចំគម្រោង |
| SMEDF | SME Development Framework | ក្របខណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម |
| Rev. | Revision | ការកែប្រែ |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| Sida | Swedish International Development Cooperation Agency | ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសស៊ុយអែដ |
| SMEs | Small and Medium Enterprises | សហគ្រាសធុនតូចនិងមធ្យម |
| TWG | Technical Working Group | ក្រុមការងារបច្ចេកទេស |
| UN | United Nations | អង្គការសហប្រជាជាតិ |
| UNDP | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNIDO | United Nations Industrial Development Organisation | អង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ |

# ១. សេចក្តីផ្តើម

បន្ទាប់ពីមានវឌ្ឍនភាពគួរជាទីចាប់អារម្មណ៍នៅក្នុងធាតុពីរនៃយុទ្ធសាស្ត្រចតុកោណ គឺ សន្តិភាពនិងសន្តិសុខ និង សមាហរណកម្មតំបន់និងអន្តរជាតិ បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមចំបង គឺជំរុញឱ្យមានវឌ្ឍនភាព ឆាប់រហ័ស នៅក្នុងធាតុផ្សេងទៀត ជាអាទិ៍ ភាពជាដៃគូអភិវឌ្ឍន៍ជាមួយរាល់ស្ថាប័នពាក់ព័ន្ធ អភិវឌ្ឍន៍សហគ្រិនភាព និង បរិយាកាសធុរកិច្ចល្អប្រសើរ។ បញ្ហាប្រឈមទាំងនេះ និង បញ្ហាប្រឈមផ្សេងទៀត ត្រូវតែដោះស្រាយ ដើម្បីពង្រីក មូលដ្ឋាននិងធានានិរន្តរភាពនៃកំណើនសេដ្ឋកិច្ច។ សហគ្រាសធុនតូចនិងមធ្យម មានសារៈសំខាន់ក្នុងការបង្កើតការងារ ធ្វើនៅកម្ពុជា (រួមទាំងការងារធ្វើដោយផ្ទាល់ខ្លួន) ហើយនិង ដើរតួនាទីយ៉ាងសំខាន់ នៅនវានុវត្តន៍ ពិពិធកម្មសេដ្ឋកិច្ច និង កំណើនសេដ្ឋកិច្ចនៅកម្ពុជា នាពេលអនាគត។

ដើម្បីធានាដល់ប្រសិទ្ធភាពនៃគោលនយោបាយ យើងត្រូវការពិនិត្យនិងវាយតម្លៃអំពីឥទ្ធិពល នៃគោលនយោបាយ ទាំងនោះ មានផលប៉ះពាល់ទៅលើក្រុមគោលដៅនានា។ ប្រសិនបើគ្មានយន្តការវាយតម្លៃ យើងមិនអាចវិនិច្ឆ័យបានថា តើគោលនយោបាយទាំងនោះ ពិតជាមានផលប៉ះពាល់ជាវិជ្ជមានទៅតាមអ្វីដែលយើងចង់បាន ឬមិនមានផលប៉ះពាល់សោះ ឬក៏មានផលប៉ះពាល់ជាអវិជ្ជមានដែលផ្ទុយពីការរំពឹងទុក។ លើសពីនេះ ដើម្បីធានាឱ្យដំណើរការវាយតម្លៃ អាចទុកចិត្តបាន និងអាចយកជាការបាន យើងត្រូវការវាស់វែងនិងផ្ទៀងផ្ទាត់ បើមិនដូច្នោះទេ នឹងអាចមាន ភាពមិនត្រឹមត្រូវ និង អសង្គតភាពនៅក្នុងដំណើរការវាយតម្លៃនោះ។

ពាក់ព័ន្ធនឹងគោលនយោបាយសហគ្រាសធុនតូចនិងមធ្យម យើងត្រូវការវាយតម្លៃថាតើគោលនយោបាយ សហគ្រាសធុនតូចនិងមធ្យម មានផលប៉ះពាល់ជាវិជ្ជមានទៅលើសហគ្រាសធុនតូចនិងមធ្យមឬទេ? ជាឧទាហរណ៍ ១- តើមាន សហគ្រាសធុនតូចនិងមធ្យមជាច្រើន ដែលបានបង្កើតថ្មីឬទេ? ២- តើមានសហគ្រាសធុនតូចនិងមធ្យម មិនផ្លូវការជាច្រើន ដែលបានចុះបញ្ជីឬមានអាជ្ញាប័ណ្ណត្រឹមត្រូវឬទេ? ៣- តើសហគ្រាសធុនតូចនិងមធ្យមនីមួយៗ មានរីកចំរើន ជាបរិមាណ ឬ វិសាលភាពនៃប្រតិបត្តិការឬទេ? យើងមិនអាចឆ្លើយតបនឹងសំណួរមូលដ្ឋានទាំងនេះ ប្រសិនបើយើង មិនមានទិន្នន័យជាក់លាក់និងទាន់ពេលវេលា ដែលអាចផ្តល់នូវព័ត៌មានចាំបាច់ អំពីវិស័យ សហគ្រាសធុនតូច និង មធ្យម និងការវិវត្តនៃសហគ្រាសធុនតូចនិងមធ្យមពីពេលមួយទៅពេលមួយ។

សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដែលមានធនធាននិងសមត្ថភាពមានកំណត់ វាជាប្រការសំខាន់ណាស់ក្នុងការធានាថាកិច្ចខិតខំប្រឹងប្រែងក្នុងការជំរុញអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យមនឹងទទួលបានលទ្ធផលជាវិជ្ជមាន ។បើមិនដូច្នោះទេឬ ក៏ផលដែលទទួលបានទាបជាងកម្រិតនៃកិច្ចខិតខំប្រឹងប្រែងពេលនោះយើងត្រូវពិចារណាឡើងវិញ នូវគោល-នយោបាយ និងការអនុវត្តគោលនយោបាយចំពោះសហគ្រាសធុនតូចនិងមធ្យម ។ កាលណាប្រទេសមួយអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យមប៉ុន្តែមិនមានមធ្យោបាយក្នុងការវាយតម្លៃថាតើយុទ្ធសាស្ត្រទាំងនោះត្រឹមត្រូវឬទេ រដ្ឋាភិបាលនឹងមិនមានមូលដ្ឋាន ដែលចាំបាច់ក្នុងការកែតម្រូវគោលនយោបាយ ឬ អនុវត្តន៍គោលនយោបាយ ដើម្បីធានាឱ្យមានលទ្ធផលខ្ពស់បំផុត ។

ការនេះមិនមែនមានន័យថា ទិន្នន័យស្តីពីសហគ្រាសធុនតូចនិងមធ្យមត្រឹមត្រូវ គឺជា ការយកចិត្តទុកដាក់ របស់អ្នកធ្វើគោលនយោបាយ តែប៉ុណ្ណោះទេ។ ស្ថាប័នពាក់ព័ន្ធជាច្រើន អាចយកចិត្តទុកដាក់ចំពោះ ទិន្នន័យនេះ ផងដែរ។ ឧទាហរណ៍ ដៃគូអភិវឌ្ឍន៍នានា ត្រូវការពត៌មានស្តីពីសហគ្រាសធុនតូចនិងមធ្យម ដើម្បីសិក្សារៀបចំ ផែនការជំនួយអភិវឌ្ឍន៍របស់ខ្លួន។ ភ្នាក់ងាររដ្ឋាភិបាលទាំងឡាយ ដែលពាក់ព័ន្ធនឹង ការធ្វើសេចក្តីសម្រេចចិត្ត ផ្នែកសេដ្ឋកិច្ចនានានឹងចាប់អារម្មណ៏ ចំពោះសារៈប្រយោជន៏នៃទិន្នន័យ សហគ្រាសធុនតូចនិងមធ្យម។ ជាពិសេស ក្នុងករណីដែលសហគ្រាសធុនតូចនិងមធ្យមតំណាង 95% នៃសហគ្រាសទាំងអស់នៅក្នុងប្រទេសភាគច្រើន។ សហគ្រាសទាំងឡាយក៏ត្រូវការស្ថិតិសហគ្រាសធុនតូចនិងមធ្យម ដើម្បីស្វែងយល់អំពីនិន្នាការរីកចំរើន នៃវិស័យនីមួយ១ ដើម្បីវាយតម្លៃនិងស្វែងយល់ពីគូប្រជែង ពីអ្នកផ្គត់ផ្គង់និងអតិថិជន និងប្រើស្ថិតិសហគ្រាសធុនតូចនិងមធ្យម ក្នុងប្រយោជន៏ផ្សេងទៀត ។វិនិយោគិនបរទេសនិងសហគ្រាសក្នុងស្រុកប្រើពត៌មាននេះ នៅក្នុងការរៀបចំផែនការអាជីវកម្មនិងយុទ្ធសាស្ត្ររបស់ខ្លួន។

## ២. សាវតានៃក្រុមការងារ គោលបំណង និង វិធីសាស្ត្រ

### ក. សាវតា

ប្រព័ន្ធស្ថិតិជាតិកម្ពុជាមានលក្ខណៈវិមជ្ឈការខ្ពស់ ។ក្រៅពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ គ្រប់ក្រសួង (ជួនកាលនាយកដ្ឋាននៃក្រសួង) និងស្ថាប័នផ្សេងទៀតមានអង្គភាពផែនការនិងស្ថិតិ ដែលទទួលបន្ទុកប្រមូលផ្តុំស្ថិតិ ។

មកដល់បច្ចុប្បន្នស្ថិតិសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជាមិនទាន់មានលក្ខណៈត្រឹមត្រូវនិងជាក់លាក់នៅឡើយដែល

បង្កបញ្ហាប្រឈមបន្ថែម ដល់ការរៀបចំអនុវត្តន៏និងការពិនិត្យវាយតម្លៃគោលនយោបាយ ដែលទាក់ទងនឹងសហគ្រាសធុនតូចនិងមធ្យម។ អាស្រ័យហេតុនេះបានជាក្រុមការងារស្ថិតិសហគ្រាសធុនតូចនិងមធ្យម មានបំណងប្រមូលស្ថិតិនៃវិស័យសហគ្រាសធុនតូចនិងមធ្យមឱ្យបានត្រឹមត្រូវ តាមរយៈទិន្នន័យដែលមានស្រាប់និងវិធីសាស្ត្រ ដែលក្រសួងពាក់ព័ន្ធនានាកំពុងអនុវត្តជាជំហានទីមួយ ក្នុងការឈានទៅកាន់ស្ថិតិសហគ្រាសធុនតូចនិងមធ្យម នៅកម្ពុជា ដែលកាន់តែ មានលក្ខណៈជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ។

ឯកឧត្តម ស៊ុយ សែម ប្រធានអនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម (SME) និង ជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល បានចេញប្រកាសមួយ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០០៧ ដើម្បីបង្កើតក្រុមការងារបច្ចេកទេសមួយស្តីពីស្ថិតិ SME (**ឧបសម្ព័ន្ធទី ១**)។ ក្រុមការងារស្ថិតិ មានភារៈកិច្ចដឹកនាំ ការងាររបស់រដ្ឋាភិបាលតាមរយៈអនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម ក្នុងការប្រមូលផ្តុំស្ថិតិសហគ្រាសធុនតូចនិងមធ្យម។

## ២. គោលបំណង និង វិសាលភាព

គោលបំណងនៃការបង្កើតក្រុមកាងារស្ថិតិ SME គឺដើម្បីប្រមូលនិងវិភាគ ស្ថិតិសហគ្រាសធុនតូច និងមធ្យម។ គោលបំណងគឺត្រូវប្រមូលស្ថិតិនេះជារៀងរាល់ឆ្នាំ។ ស្ថិតិ SME នឹងក្លាយជាឧបករណ៍មួយ សម្រាប់អ្នកធ្វើគោល-នយោបាយ។ ឧទាហរណ៏ កម្មវិធីកំណែទម្រង់គោលនយោបាយ ស្តីពីការចុះបញ្ជីពាណិជ្ជកម្ម មាននវឌ្ឍនភាព គួរជាទីកត់សម្គាល់ ក្នុងការកាត់បន្ថយចំណាយនិងនីតិវិធីសម្រាប់ការចុះបញ្ជីនៃសហគ្រាសបង្កើតថ្មី ប៉ុន្តែស្ថិតិត្រូវបង្ហាញថាតើមាន SME ប៉ុន្មានដែលបានចុះបញ្ជី បន្ទាប់ពីមានការកែទម្រង់មួយចំនួន ដើម្បីស្វែងយល់ពី កម្រិតនៃផលប៉ះពាល់ នៃការកែទម្រង់ទាំងនោះ។

កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារគឺសំដៅប្រមូលស្ថិតិដែលមានស្រាប់ពីបណ្តាក្រសួងពាក់ព័ន្ធនានា ដែលជាសមាជិកនៃ អនុគណៈកម្មាធិការ SME និង ប្រមូលព័ត៌មាន ដូចជា :

១. ចំនួន SME នៅកម្ពុជា ដោយមានបែងចែកសហគ្រិននិងអ្នកគ្រប់គ្រងទៅតាមភេទ (បុរសនិងស្ត្រី)

២. ចំនួនបុគ្គលិកសរុបរបស់ SME ដោយមានបែងចែកទៅតាមភេទ (បុរសនិងស្ត្រី)

៣. ទ្រព្យសកម្មសរុប

៤. ផលរបរប្រចាំឆ្នាំ

ការប្រមូលទិន្នន័យនេះនៅក្នុងកម្រិតទូទាំងប្រទេស។

ការប្រមូលនិងវិភាគទិន្នន័យដែលទាក់ទងនឹងសកម្មភាពសេដ្ឋកិច្ច យោងតាមប្រព័ន្ធ ISIC លេខ ២ ដូចមានសង្ខេបអំពីវិស័យសំខាន់ៗ នៅក្នុងតារាង ១ ខាងក្រោម (សម្រាប់ព័ត៌មានពិស្តារ សូមអាន **ឧបសម្ព័ន្ធទី ២**)។

## តារាង ១ : ស្ថិតិនៃបណ្តាវិស័យសេដ្ឋកិច្ចដែលប្រមូលដោយក្រុមការងារស្ថិតិ

| **លេខកូដ ISIC** | វិស័យសេដ្ឋកិច្ច | ក្រសួង ឬ ស្ថាប័នពាក់ព័ន្ធ |
|---|---|---|
| 11 - 13 | កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ |
| 31-39 | ផលិតកម្ម | ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល (លើកលែងតែ ISIC 33 ស្តីពីផលិតកម្មឈើ និងផលិតផលអំពីឈើ រួមទាំង គ្រឿងសង្ហារឹម ស្ថិតនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| 63 | ភោជនីយដ្ឋាន និង សណ្ឋាគារ | ក្រសួងទេសចរណ៍ |
| 71 | ដឹកជញ្ជូន និង ស្តុកទំនិញ | |
| 72 | ទំនាក់ទំនង | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ |
| 93 | សេវាសង្គមកិច្ច និង សហគមន៍ | ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ |

ដោយឡែក ក្រុមការងារមិនបានប្រមូលស្ថិតិនៃវិស័យសេដ្ឋកិច្ចមួយចំនួន ជាអាទិ៍ សំណង់ (ISIC 5), អគ្គិសនី ឧស្ម័ន និង ទឹក (ISIC 41-42), និង សេវាហិរញ្ញវត្ថុ អចលនៈវត្ថុ និង សេវាធានារ៉ាប់រង (ISIC 81-83)។ ក្រៅពីនេះ ស្ថិតិនេះ មិនបានបញ្ចូលទាំងស្រុងនូវស្ថិតិនៃវិស័យមិនផ្លូវការ (ដូចជា សកម្មភាពសេដ្ឋកិច្ច ដែលគ្មានអសយដ្ឋានពិតប្រាកដ សកម្មភាពសេដ្ឋកិច្ចចល័ត អ្នកប្រកបរបរបន្តិចបន្តួច អ្នកលក់តាមចិញ្ចើមថ្នល់ និង អ្នកផ្សេងទៀត) ដោយសារ ក្រសួងពាក់ព័ន្ធមានការលំបាកក្នុងការប្រមូលស្ថិតិនេះ។[១]

## គ. វិធីសាស្ត្រ

ដើម្បីសម្រួលដល់ដំណើរការប្រមូលស្ថិតិនេះ ប្រធានអនុគណៈកម្មាធិការ SME បានចេញប្រកាសមួយ ស្តីពីការបង្កើតក្រុមការងារស្ថិតិ SME ដោយមានការគាំទ្រពីក្រុមការងារ នៃគម្រោងជំនួយបច្ចេកទេស TA 4786

[១] ការសិក្សាស្វែងរកការពិតស្តីពីសេដ្ឋកិច្ចមិនផ្លូវការរបស់ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសស៊ុយអែដ

នៃធនាគារអភិវឌ្ឍន៍អាស៊ី ។ ក្រុមការងារស្ថិតិ បានជួបប្រជុំពិភាក្សា ជាច្រើនដង ដើម្បីរិះរកមធ្យោបាយប្រមូលស្ថិតិ SME ឱ្យមានលក្ខណៈជាប្រព័ន្ធនៅតាមក្រសួងនីមួយៗ។ ក្រុមការងារស្ថិតិ បានស្នើឱ្យក្រសួងនីមួយៗ ផ្តល់ស្ថិតិដែលមានស្រាប់ដែលទាក់ទងនឹង SME និង បែងចែកទៅតាមភេទ (បុរសនិងស្ត្រី) តាមដែលអាចធ្វើទៅបាន។

ប្រការសំខាន់គឺកត់សម្គាល់ថា ក្រសួងនានាមិនបានតម្រូវឱ្យប្រើវិធីសាស្ត្រថ្មីក្នុងការប្រមូលទិន្នន័យនេះឡើយ។ ក្រសួងនីមួយៗមានវិធីសាស្ត្រផ្ទាល់ខ្លួនសម្រាប់ប្រមូលទិន្នន័យ ហើយការប្រមូលនេះមិនមែនធ្វើឡើងដើម្បីធ្វើសុខដុមនីយកម្មនៃវិធីសាស្ត្រទាំងអស់នោះឡើយ។ ប៉ុន្តែការងារនេះគឺប្រមូលផ្តុំទិន្នន័យនៅតាមបណ្តាក្រសួង ដើម្បីឱ្យដឹងថាតើក្រសួងនីមួយៗ មានស្ថិតិអ្វីខ្លះ? ក្រុមការងារ បានផ្តល់ទម្រង់ស្ថិតិរួមមួយ ដើម្បីឱ្យក្រសួងទាំងនោះ រៀបចំស្ថិតិរបស់ខ្លួន។ ទម្រង់ស្ថិតិនេះ ត្រូវបានរៀបចំឡើងដោយ **អង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ** (UNIDO) កាលពីឆ្នាំ ១៩៩៧ សម្រាប់ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ដោយផ្អែកលើលេខកូដ ISIC លេខ ២ (សូមអាន**ឧបសម្ព័ន្ធទី ២**) ។

ប្រភពផ្សេងទៀតនៃទិន្នន័យដែលទាក់ទងនឹង SME បានទទួលពីធនាគារជាតិនៃកម្ពុជាទំព័រលឿង **មូលដ្ឋានទិន្នន័យឃុំ-សង្កាត់**[២] (សូមអាន**ឧបសម្ព័ន្ធទី៣**)ដែលអាចជាមូលដ្ឋានសម្រាប់ប្រៀបធៀបស្ថិតិពីបណ្តាក្រសួង។

## ៣. បញ្ហាគន្លឹះដែលទាក់ទងនឹងស្ថិតិ SME នៅកម្ពុជា

### ក. បញ្ហា និង ឧបសគ្គ

តាមរយៈជំហានដំបូងនៃការប៉ុនប៉ងប្រមូលទិន្នន័យ SME នៅកម្ពុជា របាយការណ៍នេះមិនទាន់អាចប្រើជាស្ថិតិ SME ដែលមានលក្ខណៈជាក់លាក់នៅឡើយបានទេ។ ប៉ុន្តែ ស្ថិតិ SME នេះមានលក្ខណៈប្រសើរជាងស្ថិតិដែលធ្លាប់មានកន្លងមក។ ការងាររបស់ក្រុមការងារស្ថិតិ ដូចដែលតាមឆ្លុះបញ្ចាំងនៅរបាយការណ៍នេះស្រាប់ មិនមានទិន្នន័យ ដែលថ្មីទេ ហើយការប្រមូលរៀបចំទិន្នន័យនេះ ក៏មានលក្ខណៈប្រុងប្រយ័ត្នដោយគិតគូរដល់ ភាពខុសគ្នានៃវិធី ដែល ក្រសួង និង ស្ថាប័នផ្សេងៗ កំណត់និយមន័យ SME ផងដែរ និង ប្រភេទពត៌មានអំពីសហគ្រាសទាំងឡាយ ដែល ក្រសួង និង ស្ថាប័នទាំងនោះសម្រេចចិត្តកត់ត្រា។

[២] អតីត កម្មវិធីសីលា

យោងតាមការកំណត់និយមន័យ SMEs នៅតាមបណ្តាក្រសួងពាក់ព័ន្ធមានលក្ខណៈខុសគ្នាពីក្រសួងមួយទៅក្រសួងមួយ ហាក់ដូចជាមិនមាននិយមន័យ SMEs ផ្លូវការនៅកម្ពុជា។ ស្ថានការណ៍នេះមានលក្ខណៈកាន់តែធ្ងន់ធ្ងរ ដោយសារការយល់ច្រឡំរវាងពាក្យ "សហគ្រាស" (enterprise), "អាជីវកម្ម" (business), "SME", មូលដ្ឋាន (establishment) និង ពាក្យផ្សេងទៀត ដែលច្រើនតែប្រើលាយឡំគ្នា។

បញ្ហាមួយទៀតគឺថា កម្ពុជាមានមូលដ្ឋានដែលមិនមានអាជ្ញាប័ណ្ណ (ផលិតកម្មនិងមិនមែនផលិតកម្ម) ដែលធ្វើឱ្យពិបាក ក្នុងការប៉ាន់ប្រមាណអំពីចំនួនពិតប្រាកដនៃ SME នៅកម្ពុជា។ ឧទាហរណ៍យោងតាមទិន្នន័យរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុង**តារាង ២** អ្នកកែច្នៃចំណីអាហារ មានចំនួនសរុប ២៥,៤៥៥ មូលដ្ឋាន នាដំណាច់ឆ្នាំ ២០០៦ ក្នុងចំណោមនោះ ១២,៣៥០ មូលដ្ឋាន (ប្រហែលពាក់កណ្តាល) មិនមាន លិខិតអនុញ្ញាតប្រកបអាជីវកម្មអ្វីឡើយ។ ដូចគ្នានេះដែរ ក្នុងចំណោម សហគ្រាសម៉ាស៊ីនកិនស្រូវ ចំនួន ២៣,១០៣ មូលដ្ឋាន មានសហគ្រាស ១០,៩២២ (៤៧%) មិនមានអាជ្ញាប័ណ្ណប្រកបអាជីវកម្ម។ អាស្រ័យហេតុនេះ សហគ្រាសទាំងនេះមានដំណើរការ ដោយមាន លក្ខណៈមិនផ្លូវការ។ សហគ្រាសកាត់ដេរតូចៗ មានចំនួន ១,៦៨៩ នាឆ្នាំ ២០០៦ ក្នុងចំណោមនោះប្រហែល៩០% មិនមានអាជ្ញាប័ណ្ណប្រកបអាជីវកម្ម។ចំនួនសហគ្រាស ដែលមានដំណើរការនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលរំពឹងថាមានចំនួនច្រើនជាងនេះ ហេតុនេះស្ថិតិដែលបង្ហាញនៅក្នុងរបាយការណ៍នេះសន្មត់ថា មានចំនួនតិចជាងចំនួន SME ពិតប្រាកដដែលមាន ដំណើរការនៅកម្ពុជា។

តារាង ២ : ស្ថិតិសហគ្រាសឧស្សាហកម្មតូចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឆ្នាំ ២០០៦ តាមលេខកូដ ISIC

| | | ចំនួនមូលដ្ឋាន | មានច្បាប់ (អាជ្ញាប័ណ្ណ) | |
|---|---|---|---|---|
| លេខកូដ ISIC | **វិស័យ** | **សរុប** | ចំនួនអាជ្ញាប័ណ្ណសរុប | ភាគរយនៃមូលដ្ឋានមានច្បាប់ |
| 31 | ស្បៀង ភេសជ្ជៈ និង ថ្នាំជក់ | 25,455 | 12,350 | 49% |
| 311601 | កិនស្រូវ | 23,103 | 10,922 | 47% |
| 32 | តម្បាញ,កាត់ដេរសំលៀកបំពាក់ និង ផលិតពីស្បែក | 1,689 | 167 | 10% |
| 33 | ផលិតផលពីឈើ និង អនុផលព្រៃឈើ | - | - | - |
| 34 | ក្រដាស ផលិតផលពីក្រដាស និង បោះពុម្ព និង បោះផ្សាយ | 33 | 25 | 76% |
| 35 | គីមី | 159 | 155 | 97% |
| 36 | ឧស្សាហកម្មរ៉ែ ដែលមិនមែនជាលោហៈ លើកលែងតែ ផលិតផលប្រេង និង ធ្យូងថ្ម | 797 | 652 | 82% |
| 37 | ឧស្សាហកម្មលោហៈមូលដ្ឋន | - | - | - |
| 38 | ឧស្សាហកម្មកែឆ្នៃលោហៈ | 2,380 | 1,613 | 68% |
| 39 | ឧស្សាហកម្មផ្សេង១ | 636 | 435 | 68% |
| | **សរុប** | **31,149** | **15,397** | **49%** |

ប្រភព : ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

បញ្ហាទីបី គឺដើម្បីទទួលបានស្ថិតិ SME ដែលមានលក្ខណៈពេញលេញនិងគ្រប់ជ្រុងជ្រោយ គឺមានកង្វះខាត ទិន្នន័យមូលដ្ឋានសម្រាប់អថេរសំខាន់ៗ។ ជួនកាល ក្រសួងខ្លះមានត្រឹមតែចំនួនសហគ្រាសប៉ុណ្ណោះ។ បញ្ហាទីបួន គឺការ លំបាកក្នុងការកត់ត្រាទិន្នន័យនៃសហគ្រាសខ្នាតតូចបំផុត និង អាជីវកម្មចល័ត។ សហគ្រាសទាំងនេះ ប្រហែលជា មានចំនួនច្រើនបំផុតនៅកម្ពុជា។ បញ្ហាទីប្រាំ គឺក្រុមការងារ ប្រឈមនឹងកង្វះទិន្នន័យ SME ដែលអាច ប្រៀបធៀបគ្នា និងអាចទុកចិត្តបាន។ ឧទាហរណ៍ ការប្រើលេខកូដស្តង់ដារឧស្សាហកម្មអន្តរជាតិខុសគ្នា គឺលេខកូដ ស្តង់ដារឧស្សាហកម្ម អន្តរជាតិ - កែប្រែលើកទី ២ (ISIC Rev. 2), លេខកូដស្តង់ដារឧស្សាហកម្មអន្តរជាតិ – កែប្រែ លើកទី ៣ (ISIC Rev. 3), និង លេខកូដស្តង់ដារឧស្សាហកម្មអន្តរជាតិ - កែប្រែលើកទី ៤ (ISIC Rev. 4) ក្នុងការប្រមូលទិន្នន័យ SMEs នៅតាមបណ្តាស្ថាប័នរដ្ឋផ្សេងៗ។ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល បាននិងកំពុងប្រើ

លេខកូដ ISIC Rev. 2 រីឯ វិទ្យាស្ថានជាតិស្ថិតិ បានអនុម័តប្រើលេខកូដ ISIC Rev. 4 សម្រាប់ការអង្កេតសហគ្រាសបច្ចុប្បន្នរបស់ខ្លួន (សូមអាន**ឧបសម្ព័ន្ធទី ៥** អំពីលេខកូដ ISIC Rev. 4)។

បញ្ហាមួយទៀត គឺវិធីសាស្ត្រដែលប្រើ និងជំនាញស្ថិតិ មានកម្រិតខុសគ្នាពីក្រសួងមួយទៅក្រសួងមួយ អាស្រ័យលើធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស និងកម្រិតអាទិភាពដែលកំណត់ដោយមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ ក្នុងការត្រួតពិនិត្យការប្រមូលស្ថិតិនេះ។ ជួនកាល នាយកដ្ឋាន ឬបុគ្គលនានានៅក្នុងក្រសួងទាំងនោះ មិនមានសិទ្ធិអំណាច គ្រប់គ្រាន់ក្នុងការប្រមូលទិន្នន័យ SME ដោយមានលក្ខណៈជាប្រព័ន្ធមួយ។ ក្រៅពីនេះ នៅមានបញ្ហាស្ថាប័ន កាលណា បុគ្គលដែលទទួលបន្ទុកស្ថិតិ SME ផ្លាស់ប្តូរមុខតំណែងរបស់ខ្លួន ជួនកាល មុខតំណែងទទួលបន្ទុកស្ថិតិ SME នៅទំនេរជាច្រើនខែ។ ក្រៅពីដំណើរការប្រមូលទិន្នន័យនេះ នៅមានបញ្ហានានា នៅតាមបណ្តាក្រសួង ក្នុងការ ប្រមូលរៀបចំទិន្នន័យ SME។ ទិន្នន័យទាន់ពេលវេលា ការចែកចំណាត់ថ្នាក់ ដែលមានសង្គតភាព និង ភាពខុសគ្នា នៃការបែងចែកទិន្នន័យ មានការលំបាកក្នុងការប្រៀបធៀប និង ការប្រមូលផ្តុំទិន្នន័យ SME នៅតាមបណ្តាក្រសួង។

បញ្ហាចុងក្រោយគឺជាទូទៅទិន្នន័យSMEមិនបានប្រើក្នុងគោលបំណងផ្សព្វផ្សាយឬគោលបំណងធ្វើគោល នយោបាយ។ ប៉ុន្តែ ទិន្នន័យ SME ច្រើនតែប្រើក្នុងគោលបំណងនិយ័តកម្ម (គ្រប់គ្រង) ជាអាទិ៍ ការចេញអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតផ្សេងៗ។ ការនេះគូសបញ្ជាក់ថាហេតុអ្វីបានជាមូលដ្ឋានទិន្នន័យ នៅតាមបណ្តាក្រសួង នៃអនុគណៈ-កម្មាធិការ មិនមានលក្ខណៈពេញលេញ និងខ្វះទិន្នន័យមូលដ្ឋានដែលយើងចង់បាន ទាក់ទងនឹងសហគ្រាសមួយ។

## ខ. ការអនុវត្តដោយប្រើទិន្នន័យរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ជាតំណាងឱ្យ SME នៅកម្ពុជានាពេលបច្ចុប្បន្ន

មកដល់បច្ចុប្បន្ននេះ ទិន្នន័យសហគ្រាសដែលមានស្រាប់ រួមទាំង SME នៅកម្ពុជា មិនមានលក្ខណៈរឹងមាំនៅឡើយ។ មូលហេតុមួយក្នុងចំណោមនោះ គឺថា ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និង ក្រសួងពាណិជ្ជកម្ម ប្រមូលទិន្នន័យសហគ្រាសដាច់ដោយឡែកពីគ្នា និង មិនសហការគ្នាក្នុងការចុះបញ្ជី ឬចេញអាជ្ញាប័ណ្ណ សម្រាប់សហគ្រាសធុនតូច។ ក្រៅពីនេះ ទិន្នន័យ SME របស់ក្រសួងទាំងពីរនេះ គឺច្រើនតែប្រើក្នុងគោលបំណង នៃការចេញអាជ្ញាប័ណ្ណប្រកបអាជីវកម្ម ឬការចុះបញ្ជីសកម្មភាពពាណិជ្ជកម្ម។ ទិន្នន័យនេះមិនបានបញ្ចូលសហគ្រាសធុនតូច និងមធ្យមទាំងឡាយដែល ទទួលអាជ្ញាប័ណ្ណផ្សេងៗពីក្រសួងផ្សេងទៀត នោះឡើយ។

ការអនុវត្តទូទៅ គឺប្រើទិន្នន័យអំពីសហគ្រាសផលិតកម្មរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល តំណាងឱ្យវិស័យ SME នៅកម្ពុជា ក្នុងខណៈពេលដែលមិនមានប្រព័ន្ធថ្នាក់ជាតិមួយសម្រាប់ប្រមូលទិន្នន័យ។ ជាការពិតវាមិនមែន

ជាការប្រសើរឡើយ ពីព្រោះវាមិនបានបញ្ចូលសហគ្រាសទាំងឡាយកំពុងប្រតិបត្តិការនៅក្នុងវិស័យផ្សេងទៀត ក្រៅពីសហគ្រាសផលិតកម្ម ហើយដែលទទួលអាជ្ញាប័ណ្ណពីក្រសួងផ្សេងក្រៅពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល។

## ៤. ស្ថិតិសហគ្រាសធុនតូចនិងមធ្យមនៅតាមក្រសួងនីមួយៗ

នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីបង្ហាញទិន្នន័យ SME ដែលមានលក្ខណៈប្រសើរជាងមុននៅកម្ពុជា ក្រុមការងារស្ថិតិបានប្រមូលចង់ក្រងស្ថិតិ SME ពីក្រសួងនីមួយៗដែលនៅក្នុងអនុគណៈកម្មាធិការ SME និង ពីប្រភពផ្សេងទៀតផងដែរ។ ដោយសារភាពខុសគ្នានៃនិយមន័យ វិធីសាស្ត្រ និងកត្តាផ្សេងទៀត យើងមិនអាច ប៉ាន់ប្រមាណចំនួនសរុប SME នៅកម្ពុជា ដោយបូកបញ្ចូលគ្នានូវចំនួនសហគ្រាស ពីប្រព័ន្ធទិន្នន័យនៃក្រសួងផ្សេងៗ ជាតួលេខតែមួយបានឡើយ។ ឧបសគ្គមួយក្នុងចំណោមឧបសគ្គសំខាន់ៗ ដែលធ្វើឱ្យយើងមិនអាចបូក ឱ្យចេញជាតួលេខតែមួយនេះគឺយើងមិនមានលទ្ធភាពផ្ទៀងផ្ទាត់ SME ពីមូលដ្ឋានទិន្នន័យ ពីក្រសួងមួយទៅក្រសួងមួយ។ មូលដ្ឋានទិន្នន័យទាំងនេះមានលក្ខណៈមិនពេញលេញ និងត្រូវធ្វើការសំអាត និង ធ្វើសុខដុមនីយកម្ម មុនពេលដែលអាចធ្វើការផ្ទៀងផ្ទាត់គ្នាទៅវិញទៅមកបាន។

យ៉ាងណាក៏ដោយ ក្រុមការងារបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការប្រមូលទិន្នន័យ SME ដែលមានស្រាប់ និងសង្ខេបទិន្នន័យទាំងនោះតាមក្រសួង ឬស្ថាប័នរដ្ឋនីមួយៗ (ជាចំនួនសហគ្រាសដែលក្រសួងឬស្ថាប័ននីមួយៗ កត់ត្រាក្នុងគោលបំណងផ្ទាល់របស់ខ្លួន)។ **តារាង ៣** គឺជា លទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងនេះក្នុងការប្រមូលផ្តុំស្ថិតិ SMEs ពីបណ្តាក្រសួងនិងស្ថាប័នរដ្ឋ ហើយនិងបង្ហាញស្ថិតិនៅក្នុងតារាងរួមមួយ។ មិនមែនគ្រប់ក្រសួងទាំងអស់ សុទ្ធតែអាចមានស្ថិតិគ្រប់ ដូចនៅក្នុង**តារាង ៣**នោះឡើយ។ ឧទាហរណ៍ ក្រសួងមួយចំនួន កត់ត្រាទ្រព្យសកម្មសរុប ឬ ផលរបរ។

## តារាង ៣ : សេចក្តីសង្ខេបអំពីទិន្នន័យសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា (ឆ្នាំ ២០០៦)

| ប្រភព | សហគ្រាស | | | | | បុគ្គលិក | | | ទ្រព្យសកម្មសរុប (ដុល្លារអាមេរិក) | ផលរបរ (ដុល្លារអាមេរិក) |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | សហគ្រិន | | មានច្បាប់ | | សរុប | ស្ត្រី | | | |
| | | ចំនួនជាស្ត្រី | % | ជាចំនួន | % | | ចំនួនជាស្ត្រី | % | | |
| MAFF | 26,664 | | | | | | | | | |
| MIME | 31,149 | 2,002 | 6% | 15,397 | 49% | 87,072 | 33,521 | 38% | 159.8 លាន | 649.8 លាន |
| MoT | 3,047 | 652 | 21% | 1,818 | 60% | 17,443 | 10,746 | 62% | 708.2 លាន | NA |
| MoC | *14,558 | | | | | | | | | |
| MoC | **10,862 | | | | | | | | | |
| MLVT | 125 | 14 | 11% | | | 2,267 | 635 | 28% | | |
| MEF | 48 | | | | | | | | | |
| MPTC | 150 | | | | | | | | | |
| NBC | 4,290 | | | | | | | | | |
| Tax Dept. | 55,466 | | | | | | | | | |
| Labor Dept. | 1,264 | | | | | 421,521 | 370,970 | 88% | | |
| **ប្រភពទិន្នន័យសហគ្រាសធុនតូចនិងមធ្យមផ្សេងទៀត** | | | | | | | | | | |
| ទំព័រលឿងកម្ពុជា | 20,063 | | | | | | | | | |
| សភាពាណិជ្ជកម្ម ៨ ក្នុងចំណោម ១១ | 14,520 | | | | | | | | | |
| ធនាគារអេស៊ីលីដា (ចំនួនអតិថិជន) | 170,922 | | | | | | | | | |

* ក្រសួងពាណិជ្ជកម្ម : ចុះបញ្ជីជាក្រុមហ៊ុន

** ក្រសួងពាណិជ្ជកម្ម : សហគ្រាសខ្នាតតូច

Formatted: Left
Formatted: Centered, Right: 0 cm
Deleted:
Formatted: Centered
Deleted:
Deleted:
Formatted: Left
Deleted:
Formatted: Font: 24 pt
Formatted: Centered
Formatted: Font: 24 pt
Formatted: Font: 18 pt
Formatted: Font: 24 pt
Formatted: Font: 18 pt

ផ្នែកខាងក្រោម អធិប្បាយអំពីដំណើរការប្រមូលស្ថិតិរបស់ក្រសួង និងស្ថាប័ននីមួយៗ។ ជាបឋម សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មចេញទាំងអាជ្ញាប័ណ្ណប្រកបអាជីវកម្មសម្រាប់ក្រុមហ៊ុនពាណិជ្ជកម្មជាដើម ក៏ដូចជាគ្រប់គ្រងការចុះ-បញ្ជីពាណិជ្ជកម្ម សម្រាប់អ្នកទាំងឡាយណាដែលមានបំណងបង្កើតជាក្រុមហ៊ុន។ ក្រសួងផ្សេងទៀត ដែលចេញអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតប្រកបអាជីវកម្មនានា រួមមានៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួង-ទេសចរណ៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និង សំណង់ ក្រសួងសុខាភិបាល និង ក្រសួងសាធារណៈការនិងដឹកជញ្ជូន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធនាគារជាតិនៃកម្ពុជា ជាដើម។

## ក. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបែងចែកសហគ្រាសទៅតាមផលរបរប្រចាំឆ្នាំ និងវិស័យនៃសកម្ម-ភាព សេដ្ឋកិច្ច។ ផ្អែកតាមមាត្រា ៤ នៃច្បាប់ស្តីពីសារពើពន្ធ និង ផ្នែកទី ១២.២ និង ១២.៣ នៃប្រកាស ស្តីពន្ធលើប្រាក់ចំណេញ បែងចែកអ្នកជាប់ពន្ធជាពីរប្រភេទផ្សេងគ្នា គឺ អ្នកជាប់ពន្ធរបបស្វ័យប្រកាស (Self Assessment System) និង អ្នកជាប់ពន្ធតាមរបបម៉ៅការ (Estimate Regime System) អាស្រ័យលើទម្រង់គតិយុត្តិនៃសហគ្រាស ឬកម្រិតផលរបរប្រចាំឆ្នាំ ឬ ប្រភេទសកម្មភាពអាជីវកម្ម។

សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស គឺជា សហគ្រាសទាំងឡាយណាដែលបំពេញបាននូវលក្ខខណ្ឌ ដូចខាងក្រោមនេះ :

- ទម្រង់គតិយុត្តិ : រាល់សហគ្រាសដែលមិនមែនជាសហគ្រាសឯកបុគ្គល ដូចជា សហគ្រាសរដ្ឋ ក្រុមហ៊ុនចម្រុះ ក្រុមហ៊ុនឯកជន សមូហភាពសាធារណៈ និង អង្គការឯកជន ដែលធ្វើសកម្មភាពស្វែងរកប្រាក់ចំណេញ ឬ ដែលទទួលប្រាក់ចំណូល ពីបេតិកភ័ណ្ឌខ្លួន.ដោយមិនគិតពីប្រភេទសកម្មភាពអាជីវកម្ម និង កម្រិត ផលរបរ។
- កម្រិតផលរបរ និងប្រភេទសកម្មភាពអាជីវកម្ម : សហគ្រាសដែលមានផលរបរប្រចាំឆ្នាំ :
  - ចាប់ពី 500 លានរៀលឡើងទៅ សម្រាប់ការផ្គត់ផ្គង់ទំនិញ ឬផ្គត់ផ្គង់ចម្រុះ
  - ចាប់ពី 250 លានរៀលឡើងទៅ សម្រាប់ការផ្គត់ផ្គង់សេវា ហើយនិង
  - ចាប់ពី 125 លានរៀលឡើងទៅសម្រាប់ការធ្វើកិច្ចសន្យាជាមួយរដ្ឋ។

សហគ្រាសជាប់ពន្ធតាមរបបម៉ៅការ គឺសម្រាប់តែសហគ្រាសឯកបុគ្គល ដែលមិនបំពេញលក្ខខណ្ឌជាប់ពន្ធ តាមរបបស្វ័យប្រកាសខាងលើ។

នាយកដ្ឋានពន្ធដារ មានស្ថិតិអំពីសហគ្រាសធុនតូច (របបម៉ៅការ) និង សហគ្រាសធុនមធ្យម (របបពិត) ដែលបានចុះបញ្ជីនៅនាយកដ្ឋានពន្ធដារ ។ ក្នុងឆ្នាំ ២០០៦ នាយកដ្ឋានពន្ធដារមានសហគ្រាសសរុប ៥៥,៤៦៦ ដែលបែងចែកដូចតទៅ (សម្រាប់ពត៌មានលំអិត សូមអាន**ឧបសម្ព័ន្ធទី ៦**) :

- សហគ្រាសធុនតូច មានចំនួន ៤៧,៣១៣
- សហគ្រាសធុនមធ្យម មានចំនួន ៨,១៥៣ (មិនរាប់បញ្ចូលសហគ្រាសធុនធំ ដែលមានផលរបរលើសពី ១,000 លានរៀល) ។

## ខ. ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល មានសហគ្រាសឧស្សាហកម្មចំនួន ៣១,១៤៩ នាឆ្នាំ ២០០៦ ដែលកើនឡើងប្រហែល ២៥% គិតពីឆ្នាំ ១៩៩៩ (សូមអាន**តារាង ៤**) ។ អនុវិស័យស្បៀងអាហារ ភេសជ្ជៈ និង ថ្នាំជក់ មានចំនួនច្រើនណាស់ នៅក្នុងចំណោមឧស្សាហកម្មតូច ។

**តារាង ៤ : ស្ថិតិឧស្សាហកម្មតូចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល តាម ISIC លេខ ២** (1999-2006)

| | 1999 | | 2002 | | 2003 | | 2004 | | 2005 | | 2006 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| សរុប ផ្នែកផលិតកម្ម | **24,227** | **100** | **26,920** | **100** | **25,985** | **100** | **28,131** | **100** | **29,297** | **100** | **31,149** | **100** |
| ស្បៀង ភេសជ្ជៈ និង ថ្នាំជក់ | 19,147 | 79.03 | 21,568 | 80.11 | 20,869 | 80.31 | 22,712 | 80.74 | 23,727 | 80.99 | 25,455 | 81.72 |
| តម្បាញ,កាត់ដេរ សំលៀកបំពាក់ និង ផលិតពីស្បែក | 396 | 1.63 | 1,417 | 5.26 | 1,406 | 5.41 | 1,672 | 5.94 | 1,665 | 5.68 | 1,689 | 5.42 |
| ផលិតផលពីឈើ និង អនុផលព្រៃឈើ | 814 | 3.35 | 13 | 0.05 | 13 | 0.05 | 16 | 0.06 | 2 | 0.01 | - | - |
| ក្រដាស ផលិតផល ពី ក្រដាស និង បោះពុម្ព | 23 | 0.1 | 15 | 0.06 | 21 | 0.08 | 25 | 0.09 | 31 | 0.11 | 33 | 0.11 |
| ផលិតផល គីមី | 67 | 0.28 | 275 | 1.02 | 96 | 0.37 | 120 | 0.43 | 153 | 0.52 | 159 | 0.51 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| កៅស៊ូ និង ប្លាស្ទិក | | | | | | | | | | | | |
| ឧស្សាហកម្មរ៉ែ ដែលមិនមែន លោហៈ | 777 | 3.21 | 757 | 2.82 | 681 | 2.62 | 680 | 2.42 | 719 | 2.45 | 797 | 2.56 |
| ឧស្សាហកម្ម លោហៈមូលដ្ឋាន | 24 | 0.1 | - | - | - | - | - | - | - | - | - | - |
| ឧស្សាហកម្ម កែ ច្នៃលោហៈ | 1,623 | 6.7 | 1,899 | 7.05 | 1,850 | 7.12 | 2,239 | 7.96 | 2,334 | 7.97 | 2,380 | 7.64 |
| ឧស្សាហកម្ម ផ្សេងៗ | 1,356 | 5.6 | 976 | 3.63 | 1,049 | 4.04 | 667 | 2.37 | 666 | 2.27 | 636 | 2.04 |

**ប្រភព :** សៀវភៅស្ថិតិ ឆ្នាំ ២០០១ និង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ២០០២-២០០៦

**តារាង ៥** បង្ហាញពតិមានលំអិតបន្ថែមអំពី SME ដែលបានកត់ត្រា ប្រចាំឆ្នាំ ២០០៦។ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល គឺជា ក្រសួងមួយក្នុងចំណោមក្រសួងមួយចំនួន ដែលកត់ត្រាស្ថិតិសហគ្រិននិងបុគ្គលិកភេទស្ត្រី សម្រាប់សហគ្រាសនីមួយៗ។

**តារាង ៥ : ស្ថិតិឧស្សាហកម្មតូចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រចាំឆ្នាំ ២០០៦**

| | | ចំនួនមូលដ្ឋាន | | កម្លាំងពលកម្ម | | មូលដ្ឋានមានច្បាប់ | |
|---|---|---|---|---|---|---|---|
| លេខកូដ **ISIC** | វិស័យ | **សរុប** | សហគ្រិនស្ត្រី | សរុប | ចំនួនកម្មករមធ្យម | សហគ្រាសមានច្បាប់សរុប | ភាគរយនៃសហគ្រាសមានច្បាប់ |
| 31 | ស្បៀង ភេសជ្ជៈ និង ថ្នាំជក់ | 25,455 | 1,042 | 58,512 | 2.3 | 12,350 | 49% |
| 311601 | កិនស្រូវ | 23,103 | 700 | 47,887 | 2.07 | 10,922 | 47% |
| 32 | តម្បាញ,កាត់ដេរសំលៀកបំពាក់ និង ផលិតពីស្បែក | 1,689 | 573 | 6,347 | 3.8 | 167 | 10% |
| 33 | ផលិតផលពីឈើ និង អនុផលព្រៃឈើ | - | - | - | - | - | - |
| 34 | ក្រដាស ផលិតផលពីក្រដាស និង បោះពុម្ព | 33 | 10 | 351 | 10.6 | 25 | 76% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | និង បោះផ្សាយ | | | | | | |
| 35 | គីមី | 159 | 31 | 1,448 | 9.1 | 155 | 97% |
| 36 | ឧស្សាហកម្មរ៉ែ ដែលមិនមែនជាលោហ: លើកលែងតែ ផលិតផលប្រេង និង ធ្យូងថ្ម | 797 | 120 | 8,932 | 11.2 | 652 | 82% |
| 37 | ឧស្សាហកម្មលោហ: មូលដ្ឋាន | - | - | - | - | - | - |
| 38 | ឧស្សាហកម្មកែឆ្នៃលោហ: | 2,380 | 127 | 8,243 | 3.5 | 1,613 | 68% |
| 39 | ឧស្សាហកម្មផ្សេងៗ | 636 | 99 | 3,239 | 5.1 | 435 | 68% |
| | **សរុប** | **31,149** | **2,002** | **87,072** | **2.8** | **15,397** | **49%** |

## គ. ក្រសួងទេសចរណ៍

ក្រសួងទេសចរណ៍ បានចេញអាជ្ញាប័ណ្ណជូនដល់សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន ក្លិប ភ្នាក់ងារទេសចរណ៍ និង សហគ្រាសបម្រើសេវាទេសចរណ៍ផ្សេងទៀត ចំនួន ៣,០៤៧។ ក្រសួងទេសចរណ៍ ចេញអាជ្ញាប័ណ្ណយ៉ាងតិច ប្រាំបួនប្រភេទ ខុសៗគ្នាសម្រាប់អាជីវកម្មនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទេសចរណ៍។ ចំនួនសហគ្រាស ដែលទទួលអាជ្ញាប័ណ្ណពី ក្រសួងទេសចរណ៍បានកើនឡើង ២៨,៥% ចន្លោះឆ្នាំ ២០០៥ និង ២០០៦ កើនពីចំនួន ២,៣៧២ សហគ្រាស នាឆ្នាំ ២០០៥ ដល់ចំនួន ៣,០៤៧ សហគ្រាស (សម្រាប់ពត៌មានបន្ថែម សូមអាន **ឧបសម្ព័ន្ធទី ៨**)។ ក្រសួងទេសចរណ៍ កិកត់ត្រាស្ថិតិអំពីសហគ្រិន និង បុគ្គលិកជាស្ត្រីនៅតាមសហគ្រាស ផងដែរ។

**តារាង ៦ : ស្ថិតិសហគ្រាសទេសចរណ៍ ប្រចាំឆ្នាំ ២០០៦ តាមលេខកូដ ISIC Rev. 2**

| | | ចំនួនមូលដ្ឋាន | | កម្លាំងពលកម្ម | | សហគ្រាសមានច្បាប | |
|---|---|---|---|---|---|---|---|
| លេខកូដ ISIC | វិស័យ | សរុប | សហគ្រិនជាស្ត្រី | សរុប | កម្លាំងពលកម្មជាមធ្យម | សហគ្រាសមានច្បាប់ | ភាគរយនៃសហគ្រាសមានច្បាប់ |
| 63 | ភោជនីយដ្ឋាន និង សណ្ឋាគារ | 2,242 | 487 | 12,149 | 5 | 1,400 | 62% |
| 71 | ដឹកជញ្ជូន | 805 | 165 | 5,294 | 7 | 418 | 52% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ស្តុកទំនិញ និង សេវាដឹកជញ្ជូន | | | | | | |
| | **សរុប** | **3,047** | **652** | **17,443** | **6** | 1,818 | 60% |

ប្រភព : ក្រសួងទេសចរណ៍

## ឃ. ក្រសួងពាណិជ្ជកម្ម

មកដល់ដំណាច់ឆ្នាំ ២០០៦ ក្រសួងពាណិជ្ជកម្ម មានសហគ្រាសចំនួន ១៤,៥៥៨ (រួមបញ្ចូលទាំង ក្រុមហ៊ុនឯកជន និង សហគ្រាសឯកបុគ្គល) ដែលចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មផ្ទាល់ និង មានសហគ្រាសតូចៗ ចំនួន ១០,៨៦២ ទទួលលិខិត អនុញ្ញាតឱ្យប្រកបអាជីវកម្មនៅតាមមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុងនានា។ ប៉ុន្តែ មិនមែនក្រុមហ៊ុនទាំងអស់ ១៤,៥៥៨ ចាត់ទុកជា SME នោះទេ។ យើងមិនអាចកំណត់ដឹងថាតើមានក្រុមហ៊ុនចំនួនប៉ុន្មានដែលមាន នៅក្នុងស្ថិតិចុះបញ្ជីនេះ ជា SME នោះឡើយ។ ចំពោះពតិមានលំអិតស្តីពីស្ថិតិចុះបញ្ជីតាមប្រភេទសហគ្រាស និង តាមឆ្នាំ សូមអាន**ឧបសម្ព័ន្ធទី ៩**។

**តារាង ៧ : ស្ថិតិសហគ្រាសចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម**

| ប្រភេទសហគ្រាស | ចំនួនសហគ្រាស | |
|---|---|---|
| | **2005** | **2006** |
| ក្រុមហ៊ុនឯកជន រួមទាំងក្រុមហ៊ុនវិនិយោគ | 9,999 | 11,654 |
| សហគ្រាសឯកបុគ្គល | 2,525 | 2,904 |
| សហគ្រាសខ្នាតតូចបំផុត និង ខ្នាតតូច នៅនាយកដ្ឋានពាណិជ្ជកម្មក្នុងស្រុក | 9,600 | 10,862 |
| **សរុប** | **22,124** | **25,420** |

ប្រភព : ក្រសួងពាណិជ្ជកម្ម

## ង. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

អង្កេតសង្គមកិច្ច-សេដ្ឋកិច្ច ឆ្នាំ ២០០៤ បានប៉ាន់ប្រមាណឃើញថាមានគ្រួសារចំនួន ២,៦ លាន ប្រកបរបរដាំដុះ។ ទិន្នន័យ SME ដែលទាក់ទងនឹងវិស័យកសិកម្ម មិនបានរាប់បញ្ចូល គ្រួសារដែលដាំដុះ សម្រាប់ប្រើប្រាស តែក្នុងគ្រួសារឡើយ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ កំណត់ SME ដោយផ្អែកលើទំហំផ្ទៃដីដាំដុះ គិតជាហិចតា តោន និង ឯកតាផ្សេងទៀត។ ផ្អែកលើមូលដ្ឋាននេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កត់ត្រា SME ចំនួន ២៦,៦៦៤ សហគ្រាស។ (សម្រាប់ពត៌មានពិស្តារ សូមអាន**ឧបសម្ព័ន្ធទី ១០**)

**តារាង ៨ : ស្ថិតិ SME នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (ឆ្នាំ ២០០៦)**

| លេខកូដ ISIC | វិស័យ | ចំនួនមូលដ្ឋាន |
|---|---|---|
| 11 | កសិកម្ម និង ការបរបាញ់ | 26,101 |
| 12 | ព្រៃឈើ និងការកាប់ឈើ | 212 |
| 13 | នេសាទ | 312 |
| 33 | ផលិតកម្មឈើ និងផលិតផលអំពីឈើ | 19 |
| | **សរុប** | **26,644** |

**ប្រភព :** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## ច. ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ផ្តល់អាជ្ញាប័ណ្ណដល់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្នុងឆ្នាំ ២០០៦ មានអង្គភាពបណ្តុះបណ្តាលវិជ្ជាជីវៈឯកជននិងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១២៥ ទទួលអាជ្ញាប័ណ្ណ និង មានចំនួនបុគ្គលិកសរុបចំនួន ២,២៦៧ នាក់។ ក្នុងចំណោមនោះ មានបុគ្គលិកជាស្ត្រីចំនួនត្រឹមតែ ២៨% ប៉ុណ្ណោះ។ (សម្រាប់ពត៌មានពិស្តារ សូមអាន**ឧបសម្ព័ន្ធទី ១១**)

## ឆ. ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ បានចេញអាជ្ញាប័ណ្ណសម្រាប់ហាងអ៊ិនធើណិតកាហ្វេ។ ក្នុងឆ្នាំ ២០០៦ ក្រសួងបានចេញអាជ្ញាប័ណ្ណចំនួន ១៥០ នៅក្នុងខេត្ត-ក្រុងចំនួន ១៤។[៣] (សម្រាប់ពត៌មានពិស្តារ សូមអាន**ឧបសម្ព័ន្ធទី ១២**)

## ជ. ស្ថិតិបន្ថែម

លេខកូដ ISIC 00 តាងឱ្យសកម្មភាពដែលមិនមានថែង ហើយសហគ្រាសមួយចំនួនអាចចាត់ទុកជា SME អាស្រ័យលើនិយមន័យដែលប្រើ។ ក្នុងឆ្នាំ ២០០៦ ធនាគារជាតិនៃកម្ពុជា បានចេញអាជ្ញាប័ណ្ណចំនួន ៤,២៩០ ដល់អាជីវករប្តូរប្រាក់ និង លក់ដូរលោហៈមានតម្លៃ (មាស និង គ្រឿងអលង្ការ) ទូទាំងប្រទេស។

**តារាង ៩: ស្ថិតិអាជីវករប្តូរប្រាក់ និង លក់មាស (ឆ្នាំ ២០០៦)**

| លេខកូដ ISIC | វិស័យ | ចំនួនមូលដ្ឋាន |
|---|---|---|
| 00 | អាជីវករប្តូរប្រាក់ | 647 |
| 00 | អាជីវករលក់មាស | 3,643 |
| | **សរុប** | 4,290 |

**ប្រភព :** ធនាគារជាតិនៃកម្ពុជា

[៣] នាយកដ្ឋានទូរគមនាគមន៍និយ័ត និង ទំនាក់ទំនងអន្តរជាតិ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

# ៥. ជម្រើសសម្រាប់ការប្រមូលស្ថិតិសហគ្រាសធុនតូចនិងមធ្យមនាពេលអនាគត

ការរៀបចំប្រមូលទិន្នន័យ SME ពីក្រសួងនានាដែលជាសមាជិកនៃអនុគណៈកម្មាធិការ SME មានលក្ខណៈ មិនល្អប្រសើរឡើយ ដោយសារភាពខុសគ្នានៃវិធីប្រមូលទិន្នន័យ និយមន័យមិនមានលក្ខណៈសង្គតភាព រវាងក្រសួងនានាកង្វះទម្រង់គំរូដែលមានលក្ខណៈដូចគ្នា និងមានការលំបាក ក្នុងការផ្ទៀងផ្ទាត់ SME នៅក្នុងមូលដ្ឋានទិន្នន័យផ្សេងៗ។ អាស្រ័យហេតុនេះ អនុគណៈកម្មាធិការ SME មានជម្រើសសំខាន់បី ក្នុងការប្រមូលស្ថិតិ SME នាពេលអនាគត គឺ **ជម្រើសទី ១ :** បន្តវិធីសាស្ត្រប្រមូលទិន្នន័យ នៅតាមក្រសួងនានាដែលអនុវត្តបច្ចុប្បន្ន **ជម្រើសទី២ :** អនុវត្តវិធីសាស្ត្រនិងទម្រង់គំរូថ្មីមួយដែលមានលក្ខណៈស្តង់ដា សម្រាប់រាល់ ក្រសួងដែល ជាសមាជិក នៃ អនុគណៈកម្មាធិការ SME និង **ជម្រើសទី៣ :** ធ្វើការប្រមូលស្ថិតិ SME ក្នុងកម្រិតថ្នាក់ជាតិ ដោយសហការ ជាមួយវិទ្យាស្ថានជាតិស្ថិតិ និង អង្គការ JICA ក្នុងការធ្វើជំរឿននិងអង្កេតសហគ្រាសនាពេលខាងមុខនេះ។

ជម្រើសទាំងបីនេះ ត្រូវបានលើកឡើងក្នុងពេលប្រជុំជាមួយក្រុមការងារស្ថិតិកាលពីខែកញ្ញា ឆ្នាំ២០០៧។ គុណសម្បត្តិ និង គុណវិបត្តិនៃជម្រើសនីមួយៗ ត្រូវបានបង្ហាញ ហើយសមាជិក ក្រុមការងារស្ថិតិ ត្រូវបាន ស្នើឱ្យ ពិគ្រោះ ពិភាក្សា និងផ្តល់អនុសាសន៍ដល់អនុគណៈកម្មាធិការ SME អំពីជម្រើសណាដែលសមាជិកក្រុមការងារស្ថិតិគិតថាជា វិធីសាស្ត្រប្រសើរបំផុតក្នុងការប្រមូលស្ថិតិ SME នាពេលអនាគត។ ជម្រើសទាំងនេះ មានសង្ខេប ដូចតទៅ :

**ជម្រើសទី១** វិធីសាស្ត្រប្រមូលទិន្នន័យបច្ចុប្បន្ន មិនផ្តល់ស្ថិតិ SME នៅកម្ពុជា ដែលត្រឹមត្រូវនិងជាក់លាក់ក្នុងកម្រិតថ្នាក់ជាតិឡើយ។ ការបន្តអនុវត្តវិធីសាស្ត្រប្រមូលស្ថិតិបច្ចុប្បន្ន នៅតាមក្រសួងនានា នឹងផ្តល់ទិន្នន័យដែលមានប្រយោជន៍សម្រាប់ប្រើនៅសាមីក្រសួងទាំងនោះតែប៉ុណ្ណោះ (ជាពិសេស សម្រាប់គោលបំណង ចេញអាជ្ញាប័ណ្ណ) ប៉ុន្តែវាមិនសូវមានពត៌មានច្រើនអំពី SME នៅកម្ពុជា។ **ជម្រើសទី២** គឺការប្រើទម្រង់គំរូ សម្រាប់ការប្រមូលទិន្នន័យ SME នៅតាមបណ្តាក្រសួងដែលជាសមាជិកនៃអនុគណៈកម្មាធិការ SME។ ជម្រើសតី២នេះនឹងតម្រូវឱ្យមានការកែទម្រង់ច្រើន និងតម្រូវឱ្យធនធាន សម្រាប់នាយកដ្ឋាន ដែលទទួលបន្ទុកប្រមូលទិន្នន័យ។ ដើម្បីប្រើទម្រង់គំរូនិងកម្រងសំណួរថ្មី យើងត្រូវការមិនត្រឹមតែ មូលដ្ឋាន ទិន្នន័យដែលលក្ខណៈប្រសើរជាង និងបំលែងពីប្រព័ន្ធទិន្នន័យចាស់ប៉ុណ្ណោះទេ ថែមទាំងត្រូវការមន្ត្រី និង ការបណ្តុះបណ្តាលបន្ថែម។ ការចំណាយ ដែលទាក់ទងនឹងការកែទម្រង់នេះមានកម្រិតខ្ពស់ ហើយលទ្ធភាពជោគជ័យ នៅតាមបណ្តាក្រសួង មានកម្រិតទាប។ **ជម្រើសទី៣** គឺសហការជាមួយវិទ្យាស្ថានជាតិស្ថិតិ និង អង្គការ JICA អំពីការធ្វើជំរឿននិងអង្កេត សហគ្រាសនាពេលខាងមុខ ទំនងជាវិធីដែលមានប្រសិទ្ធភាពខ្ពស់បំផុតក្នុងការប្រមូលស្ថិតិ SME ថ្នាក់ជាតិ ដ៏ត្រឹម ត្រូវមួយ។

យោងតាមច្បាប់ស្ដីពីស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ ត្រូវធ្វើជំរឿនសហគ្រាសរៀងរាល់ ១០ ឆ្នាំ។ ជំរឿនសហគ្រាស ត្រូវបានគ្រោងនឹងធ្វើ នៅឆ្នាំ ២០១១ ប៉ុន្តែ អង្កេតនានា ត្រូវបានធ្វើជាបន្តបន្ទាប់ចាប់តាំងពីខែកញ្ញា ឆ្នាំ ២០០៧ នៅរាជធានីភ្នំពេញ និង នៅបណ្ដាខេត្តផ្សេងទៀត ក្នុងឆ្នាំ ២០០៨។ អនុគណៈកម្មាធិការ មានឱកាស ក្នុងការចូលរួមធ្វើអង្កេតទាំងនេះ ហើយក៏ដូចជា ជំរឿនផងដែរ។ ដោយសារតែអង្កេតរបស់វិទ្យាស្ថានជាតិស្ថិតិ និង អង្គការ JICA នឹងប្រមូលតែទិន្នន័យមួយចំនួន (មិនមែនទិន្នន័យទូទៅ) អំពីអសយដ្ឋាន ប្រភេទអាជីវកម្ម និង ចំនួនកម្មករ អនុគណៈកម្មាធិការ SME អាចមានលទ្ធភាព ក្នុងការពង្រីកវិសាលភាពនៃអង្កេតនេះ តាមរយៈ ការបញ្ចូលសំណួរនានា (ដូចជា ប្រភេទសំណួរឬសូចនាករ) ដែលបម្រើឱ្យគោលបំណង របស់អនុគណៈកម្មាធិការ។ កម្រងសំណួរ អាចរៀបចំឡើងដោយសហការជាមួយអង្គការ JICA និងវិទ្យាស្ថានជាតិស្ថិតិ នៅក្រោម ជំនួយ បច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលចាប់ផ្ដើមក្នុងឆ្នាំ ២០០៨ ខាងមុខនេះ ហើយការអង្កេត នឹងត្រូវស្ថិត នៅក្រោមការគ្រប់គ្រងរបស់ក្រុមការងារនៃវិទ្យាស្ថានជាតិស្ថិតិនិងអង្គការ JICA ដែលកំពុងធ្វើជំរឿន និងអង្កេត សហគ្រាសនេះ។ អង្កេតនេះអាចធ្វើឡើងជារៀងរាល់ឆ្នាំ ដើម្បីពិនិត្យតាមដានការអភិវឌ្ឍនៃវិស័យ SME និង បរិយាកាសធុរកិច្ច។ វាអាចជាគម្រោងមួយ នៃកម្មវិធីជំនួយអភិវឌ្ឍន៍ SME ថ្មីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បី បង្កើតមូលដ្ឋានទិន្នន័យ ថ្នាក់ជាតិមួយស្ដីពី SME នៅកម្ពុជា ហើយវាក៏ជាមូលដ្ឋានទិន្នន័យនៃ SME ទាំងអស់ ទូទាំងប្រទេស ពីព្រោះមូលដ្ឋានទិន្នន័យនេះ ទទួលបានពីអង្កេតថ្នាក់ជាតិមួយ។

មានតែវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ SME ថ្នាក់ជាតិ ដូចជាវិធីសាស្ត្រធ្វើជំរឿននិងអង្កេតសហគ្រាសរបស់ វិទ្យាស្ថានជាតិស្ថិតិ និង អង្គការ JICA ទេ ដែលនឹងផ្ដល់នូវស្ថិតិត្រឹមត្រូវ SME នៅកម្ពុជា។ វិទ្យាស្ថានជាតិស្ថិតិ និង អង្គការ JICA នឹងជ្រើសបាន់គំរូតាមខេត្ត អាស្រ័យហេតុនេះ មិនត្រឹមតែផ្ដល់ទិន្នន័យត្រឹមត្រូវថ្នាក់ជាតិប៉ុណ្ណោះ ថែមទាំងផ្ដល់នូវទិន្នន័យតាមខេត្ត ហេតុនេះយើងអាចយល់ដឹងពីភាពខុសគ្នានៅតាមបណ្ដាខេត្ត ផងដែរ។

សេចក្ដីសង្ខេបអំពីគុណសម្បត្តិនិងគុណវិបត្តិនៃជម្រើសនានាសម្រាប់ការប្រមូលស្ថិតិ SME នាពេលអនាគត :

**ជម្រើសទី១ :** បន្តអនុវត្តវិធីសាស្ត្របច្ចុប្បន្ននៅតាមបណ្ដាក្រសួង

**គុណសម្បត្តិ :**

- រក្សារចនាសម្ព័ន្ធនិងដំណើរការដដែល។
- ការបន្តប្រមូលទិន្នន័យដែលមានប្រយោជន៍ដល់ក្រសួងនីមួយៗ។
- មិនមានចំណាយ។

**គុណវិបត្តិ :**

- មិនអាចមានស្ថិតិសហគ្រាសធុនតូចនិងមធ្យមថ្នាក់ជាតិដែលត្រឹមត្រូវបានឡើយ ។
- ខ្វះសូចនាករសំខាន់ៗជាច្រើន ។
- ទិន្នន័យមិនអាចប្រៀបធៀបគ្នាបានរវាងបណ្តាក្រសួង ។
- មិនមានសង្គតភាពអំពីនិយមន័យនិងវិធីសាស្ត្រសម្រាប់ការប្រមូលទិន្នន័យ ។

**ជម្រើសទី២ :** អនុវត្តគំរូស្ថិតិសហគ្រាសធុនតូចនិងមធ្យមថ្មីនៅតាមបណ្តាក្រសួង

**គុណសម្បត្តិ :**

- អាចប្រើនិយមន័យនិងវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យប្រកបដោយសង្គតភាព ។
- អាចប្រៀបធៀបនិងប្រមូលទិន្នន័យពីបណ្តាក្រសួង ។
- មានឱកាសប្រមូលសូចនាករថ្មីដែលអនុគណៈកម្មាធិការ SME ត្រូវការ ។

**គុណវិបត្តិ :**

- ចំណាយខ្ពស់លើការបណ្តុះបណ្តាលបុគ្គលិកឡើងវិញ និងរៀបចំវិធីសាស្ត្រថ្មីក្នុងការប្រមូលទិន្នន័យ ។
- អាចត្រូវការធនធានបន្ថែមដើម្បីប្រមូលទិន្នន័យនៅថ្នាក់មូលដ្ឋាន ។
- ដាច់ទិន្នន័យដែលមានស្រាប់នៅតាមបណ្តាក្រសួង ដូចជា ក្រសួងពាណិជ្ជកម្ម និង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ជម្រើសទី៣ :** សហការជាមួយវិទ្យាស្ថានជាតិស្ថិតិ និង អង្គការ JICA ក្នុងការធ្វើជំរឿន និង អង្កេតសហគ្រាស

**គុណសម្បត្តិ :**

- មានស្ថិតិ SME ត្រឹមត្រូវអនុលោមតាមច្បាប់ស្តីពីស្ថិតិ ។
- ផ្តល់សូចនាករ SME ចាំបាច់សម្រាប់អនុគណៈកម្មាធិការ SME និងអ្នកធ្វើគោលនយោបាយ ។
- ប្រើជំនាញឯកទេស និងធនធានមនុស្សដែលមានស្រាប់នៅវិទ្យាស្ថានជាតិស្ថិតិ និងអង្គការ JICA ។
- បង្ហាញនូវភាពសហការនិងសហប្រតិបត្តិការរវាងអ្នកផ្តល់ជំនួយ ។
- អនុញ្ញាតឱ្យក្រសួងនានាបន្តប្រមូលស្ថិតិផ្សេងទៀត ដើម្បីបំពេញគោលបំណងផ្ទាល់របស់សាម៉ីក្រសួង ។

**គុណវិបត្តិ :**

- ចំណាយខ្ពស់ជាងជម្រើសទីមួយ ។

ក្រុមការងារស្ថិតិ និងសហប្រធាន មកពីវិទ្យាស្ថានជាតិស្ថិតិ និង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ផ្តល់ជាអនុសាសន៍ដល់អនុគណៈកម្មាធិការ SME នូវ **ជម្រើសទី៣** គឺសហការជាមួយវិទ្យាស្ថានជាតិស្ថិតិ និងអង្គការ JICA ក្នុងការធ្វើជំរឿន និងអង្កេតសហគ្រាស ដែលជាវិធីសាស្ត្រប្រសើរបំផុតក្នុងការប្រមូលស្ថិតិ SME ដែលចាំបាច់នាពេលអនាគត សម្រាប់ការធ្វើគោលនយោបាយ និងគោលបំណងសំខាន់ៗផ្សេងទៀត។ **ជម្រើសទី៣** គឺជាវិធីដ៏មានប្រសិទ្ធភាព និងត្រឹមត្រូវបំផុតក្នុងការផ្តល់ស្ថិតិនិងពត៌មានពេញលេញអំពី SME នៅកម្ពុជា ដែលអនុគណៈកម្មាធិការ SME និងអ្នកពាក់ព័ន្ធផ្សេងទៀត កំពុងតែត្រូវការ ។

# ឯកសារពិគ្រោះ និង ឯកសារផ្សេងទៀត


- Abbasi, Zia, et al. 2005. "Statistical Capacity Building: Case Studies and Lessons Learned," IMF.
- EIC. 2005. *The Informal Economy in Cambodia: An Overview*. January-March 2005.
- EIC. 2006. Handbook on Decent Work in the Informal Economy in Cambodia. ILO.
- International Monetary Fund. 2007. "Cambodia: Selected Issues and Statistical Appendix," Country Report No. 07/291.
- JICA. 2007. Cambodia Investment Guidebook.
- JICA. 2007. "Cambodia: Country Gender Profile."
- Kang Chandararot. 2004. "The Enabling Environment for Micro, Small, and Medium Enterprises in Cambodia: An Assessment Based on Surveys in Urban Areas in Kampong Cham, Kampong Chhnang, and Kampot." The Asia Foundation.
- Flodman Becker, Kristina. 2004. "The Informal Economy: Sida's Fact Finding Study."
- Kusakabe, Kyoko. 2006. "On the Board of Legality: A Review of Studies on Street Vending in Phnom Penh, Cambodia," Informal Economy, Poverty and Employment. International Labour Organisation.
- Lindner, Andreas. 2004. "SME Statistics: Towards More Systematic Statistical Measurement of SME Behavior," UN Statistics Division. Retrieved on 20 July 2007 from http://unstats.un.org/unsd/industry/meetings/eg2005/AC105-22.PDF.
- Lundstrom, Susanna and Per Ronnas. 2006. "Employment and Growth in Cambodia – An Integrated Economic Analysis," SIDA Country Economic Report, 2006:2.
- Ministry of Agriculture, Forestry and Fisheries. Annual Report 2006.
- Ministry of Industry, Mines and Energy. Annual Report 2006.
- Ministry of Planning. 2005. "Statistical Master Plan for Cambodia."
- Ministry of Tourism. Annual Report 2006.
- Ministry of Women's Affairs. 2006. "Statistics on Gender Situation of Kampong Cham."
- National Institute of Statistics. 2003. "Survey of Industrial Establishment 2000."
- National Institute of Statistics. 2006. Cambodian Statistical Yearbook 2006.
- National Institute of Statistics. 2007. "Statistical Master Plan for Cambodia."
- Pak Sereivathana. 2007. "Financial Sector Diagnostic – Cambodia." International Finance Corporation.

- Royal Government Cambodia. 2005. “SME Development Framework.”
- Royal Government Cambodia. 2005. “Statistics Law.”
- SME Subcommittee. 2006. SME Annual Report 2006.
- United Nations Statistics Division. 1968. “International Standard Industrial Classification of all Economic Activities, Second Revision (ISIC, Rev.2).” Retrieved on 16 August 2007 from http://unstats.un.org/unsd/cr/registry/regcst.asp?Cl=8
- United Nations Statistics Division. 2006. “International Standard Industrial Classification, Fourth Revision (ISIC, Rev.4).” Retrieved on 16 August 2007 from http://unstats.un.org/unsd/cr/registry/regcst.asp?Cl=27.

# ឧបសម្ព័ន្ធទី ១ :

# ប្រកាសស្តីពីការបង្កើតក្រុមការងារស្ថិតិសហគ្រាសធុនតូចនិងមធ្យម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ៧០១ ឧ.រ.ថ.អ.ក.ល.ប.ក

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ មិថុនា ឆ្នាំ ២០០៧

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារស្ថិតិសហគ្រាសធុនតូច និង មធ្យម ដែលស្ថិតក្រោមគំរោងអភិវឌ្ឍន៍សហគ្រាសធុនតូច និង មធ្យម របស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ 2129-CAM(SF)

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសេចក្តីសំរេចលេខ ៤៤ សសរ. ចុះថ្ងៃទី២៦ ខែ សីហា ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតគណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន
- បានឃើញសេចក្តីសំរេចលេខ ៤៦ សសរ. ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ២០០៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតអនុគណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន
- អនុលោមតាមតម្រូវការរបស់គំរោងប្រាក់កម្ចីធនាគារអភិវឌ្ឍន៍អាស៊ី 2129-CAM(SF)

## សំរេច

**ប្រការ១** : លោក លោកស្រី អ្នកនាងកញ្ញា ជាមន្ត្រីរាជការ ដូចមានរាយនាមខាងក្រោម ត្រូវបានបង្កើត ជាក្រុមការងារស្ថិតិសហគ្រាសធុនតូច និង មធ្យម :

| | | | | |
|---|---|---|---|---|
| ១- | លោក | **នួន ថារ៉ា** | ប្រធាននាយកដ្ឋាន នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សហប្រធាន |
| ២- | លោក | **មិច កន្ទុល** | ប្រធាននាយកដ្ឋាន នៃវិទ្យាស្ថានជាតិស្ថិតិ | សហប្រធាន |
| ៣- | លោកស្រី | **នង កណ្ណិកា** | អនុប្រធាននាយកដ្ឋាន នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៤- | កញ្ញា | **តែ ទួចលីម** | អនុប្រធាននាយកដ្ឋាន នៃក្រសួងកិច្ចការនារី | សមាជិក |
| ៥- | លោកស្រី | **ឆា ម៉ារ៉ាវី** | អនុប្រធាននាយកដ្ឋាន នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦- | លោកស្រី | **ជួន មណីរដ្ឋ** | ប្រធានការិយាល័យ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៧- | កញ្ញា | **ម៉ុល សុខចាន់** | អនុប្រធានការិយាល័យ នៃក្រសួងទេសចរណ៍ | សមាជិក |
| ៨- | លោក | **អ៊ូ ជួបកុសល** | អនុប្រធានការិយាល័យ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៩- | លោក | **ប៊ុង គោរ** | អនុប្រធានការិយាល័យ នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | សមាជិក |

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

**ប្រការ២** ៖ ក្រុមការងារស្ថិតិ នេះមានភារៈកិច្ចប្រមូលទិន្នន័យស្ថិតិ សហការជាមួយក្រុមជំនាញការធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងលេខាធិការដ្ឋានរបស់អនុគណៈកម្មាធិការសហគ្រាសធុនតូច និង មធ្យម ដើម្បី រៀបចំចងក្រងស្ថិតិសហគ្រាសធុនតូច និងមធ្យម ទូទាំងប្រទេស ។

**ប្រការ៣** ៖ ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន

- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សម៉ីជន " ដើម្បីអនុវត្តន៍ "
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ២ :

## លេខកូដស្តង់ដារឧស្សាហកម្មអន្តរជាតិ - កែប្រែលើកទី២ (ISIC Rev. 2)

# លេខកូដស្តង់ដារឧស្សាហកម្មអន្តរជាតិ ~ កែប្រែលើកទី ២ (ISIC-Rev.2)[១]

## ផ្នែកទី១ : កសិកម្ម ប្រមាញ់ ព្រៃឈើ និង នេសាទ

11
- កសិកម្ម និង បរបាញ់សត្វ
  - 111
  - ផលិតកម្មកសិកម្ម និង បសុសត្វ
  - 112
  - សេវាកម្មកសិកម្ម
  - 113
  - បរបាញ់ និងដាក់អន្ទាក់សត្វ

12
- ព្រៃឈើ និង ការកាប់ឈើ
  - 121
  - ព្រៃឈើ
  - 122
  - ការកាប់ឈើ

13
- 130
- នេសាទ

## ផ្នែកទី២ : ការជីកយករ៉ែ និង ការបំបែកថ្ម

21
- 210
- រ៉ែធ្យូងថ្ម

22
- 220
- ការបូមយកប្រេងឆៅ និង ឧស្ម័នធម្មជាតិ

23
- 230
- ការជីកយករ៉ែលោហៈ

29
- 290
- ការជីកយករ៉ែផ្សេងទៀត

## ផ្នែកទី៣ : ផលិតកម្ម

31
ផលិតកម្មចំណីអាហារ ភេសជ្ជៈ និង ថ្នាំជក់
311-312
ផលតិកម្មចំណីអាហារ
313
វិស័យផលិតភេសជ្ជៈ
314
ផលិតកម្មថ្នាំជក់
32
វិស័យវាយនភណ្ឌ សំលៀកបំពាក់ និងផលិតផលស្បែក
321
ផលិតកម្មវាយនភណ្ឌ
322
ផលតិកម្មសំលៀកបំពាក់ លើកលែងតែ ស្បែកជើង
323
ផលិតកម្មស្បែក និងផលិតផលអំពីស្បែក រោមសត្វ លើកលែងតែ សំលៀកបំពាក់
324
ផលិតកម្មស្បែកជើង លើកលែងតែ ផលិតផលកៅស៊ូស្វិត ឬ ស្បែកជើងកៅស៊ូ
33
ផលិតកម្មឈើ និងផលិតផលអំពីឈើ រួមទាំងគ្រឿងសង្ហារឹម
331
ផលិតកម្មឈើ និងផលិតផលអំពីឈើ និង ត្បាញ លើកលែងតែ គ្រឿងសង្ហារឹម
332
ផលិតកម្មគ្រឿងសង្ហារឹម លើកលែងតែគ្រឿងសង្ហារឹមអំពីលោហៈសុទ្ធសាធ
34
ផលិតកម្មក្រដាស់ និង ផលិតផលអំពីក្រដាស់ បោះពុម្ព និង បោះផ្សាយ
341
ផលិតកម្មក្រដាស់ និងផលិតផលធ្វើអំពីក្រដាស់
342
វិស័យបោះពុម្ព និង បោះផ្សាយ
35
ផលិតកម្មសារធាតុគីមី និង ផលិតផលអំពីជាតិគីមី ផលិតផលចម្រាញ់ពីប្រេងកាត ធ្យូងថ្ម
ផលិតផលអំពីជ័រកៅស៊ូ និង ប្លាស្ទិក
351

ផលិតកម្មគីមីឧស្សាហកម្ម
352
ផលិតកម្មគីមីផ្សេងទៀត
353
ផលិតកម្មចម្រាញ់ប្រេងកាត
354
ផលិតកម្មទំនិញផ្សេងៗអំពីប្រេងកាតនិងធ្យូង
355
ផលិតកម្មផលិតផលអំពីកៅស៊ូ
356
ផលិតកម្មផលិតផលអំពីប្លាស្ទិក ដែលមិនមានចែងផ្សេងទៀត
36
ផលិតកម្មផលិតផលមិនមែនរ៉ែលោហៈ លើកលែងតែ ផលិតផលអំពីប្រេងកាតនិងធ្យូងថ្ម
361
ផលិតកម្មចានឆ្នាំង និងផលិតផលអំពីដី
362
ផលិតកម្មកញ្ចក់ និងផលិតផលអំពីកញ្ចក់
369
ផលិតកម្មមិនមែនរ៉ែលោហៈផ្សេងទៀត
37
ការផលិតលោហៈធាតុមូលដ្ឋាន
371
ផលិតកម្មដែកថែប និង ដែកមូលដ្ឋាន
372
ផលិតកម្មលោហៈមិនមានជាតិដែក
38
ផលិតកម្មលោហៈកែច្នៃ ម៉ាស៊ីន និង ឧបករណ៍
381
ផលិតកម្មលោហៈកែច្នៃ លើកលែងតែ គ្រឿងម៉ាស៊ីន និង ឧបករណ៍
382
ការផលិតគ្រឿងម៉ាស៊ីន លើកលែងតែ គ្រឿងអគ្គិសនី
383
ការផលិតបរិក្ខារអគ្គិសនី
384
ផលិតកម្មឧបករណ៍ដឹកជញ្ជូន
385

ផលិតកម្មឧបករណ៍វិជ្ជាជីវៈ វិទ្យាសាស្ត្រ និងឧបករណ៍វាស់ស្ទង់ផ្សេងទៀត និង ផលិតផលអំពីរូបថត និង អុបទិក

39

390

វិស័យផលិតកម្មផ្សេងទៀត

## ផ្នែកទី៤ : អគ្គិសនី ឧស្ម័ន និង ទឹក

41

410

អគ្គិសនី ឧស្ម័ន និង ចំហាយទឹក

42

420

ការផលិតនិងផ្គត់ផ្គង់ទឹក

## ផ្នែកទី៥ : សំណង់

50

500

សំណង់

## ផ្នែកទី៦ : ពាណិជ្ជកម្មលក់ដុំ និងលក់រាយ ភោជនីយដ្ឋាន និង សណ្ឋាគារ

61

610

អាជីវកម្មលក់ដុំ

62

620

អាជីវកម្មលក់រាយ

63

ភោជនីយដ្ឋាន និង សណ្ឋាគារ

631

ភោជនីយដ្ឋាន ហាងកាហ្វេ និង អាហារដ្ឋានផ្សេងទៀត

632

សណ្ឋាគារ ផ្ទះសំណាក់ ជំរំ និង កន្លែងស្នាក់នៅផ្សេងទៀត

## ផ្នែកទី៧ : ការដឹកជញ្ជូន ការស្តុកទំនិញ និង ទំនាក់ទំនង

71
ការដឹកជញ្ជូន និង ការស្តុកទំនិញ
711
ការដឹកជញ្ជូនតាមផ្លូវគោក
712
ការដឹកជញ្ជូនតាមផ្លូវទឹក
713
ការដឹកជញ្ជូនតាមផ្លូវអាកាស
719
សេវាកម្មដែលទាក់ទងនឹងការដឹកជញ្ជូន
72
720
ទំនាក់ទំនង

## ផ្នែកទី៨ : សេវាហិរញ្ញវត្ថុ ធានារ៉ាប់រង អចលនៈវត្ថុ និង សេវាគាំទ្រអាជីវកម្ម

81
810
ស្ថាប័នហិរញ្ញវត្ថុ
82
820
សេវាធានារ៉ាប់រង
83
សេវាអចលនៈវត្ថុ និងសេវាគាំទ្រផ្សេងទៀត
831
សេវាអចលនៈវត្ថុ
832
សេវាគាំទ្រអាជីវកម្ម លើកលែងតែ ភតិសន្យា និង ការជួលម៉ាស៊ីន និងឧបករណ៍
833
ភតិសន្យា និង ការជួលម៉ាស៊ីន និងឧបករណ៍

## ផ្នែកទី៩ : សេវាសហគមន៍ សង្គមកិច្ច និង សេវាបុគ្គល

91
910
សេវារដ្ឋបាលសាធារណៈ និង ការពារ

92

920

សេវាអនាម័យ និង សេវាប្រហាក់ប្រហែល

93

សេវាសហគមន៍និងសង្គមកិច្ច

931

សេវាអប់រំ

932

វិទ្យាស្ថានស្រាវជ្រាវនិងវិទ្យាសាស្ត្រ

933

សេវាវេជ្ជសាស្ត្រ ទន្តសាស្ត្រ និងសេវាពេទ្យសត្វ និងសេវាសុខភាពផ្សេងទៀត

934

សេវាសុខមាលភាពសង្គម

935

សមាគមធុរកិច្ច សមាគមវិជ្ជាជីវៈ និង សហជីព

939

សេវាសង្គមកិច្ចនិងសហគមន៍ផ្សេងទៀត

94

សេវាកំសាន្តនិងវប្បធម៌ Recreational and Cultural Services

941

ភាពយន្ត និងសេវាកំសាន្តផ្សេងទៀត

942

បណ្ណាល័យ សារៈមន្ទីរ សួនរុក្ខសាស្ត្រ និងសួនសត្វ និងសេវាវប្បធម៌ផ្សេងទៀត

949

សេវាកំសាន្តផ្សេងទៀត

95

សេវាបុគ្គល និង សេវាតាមគ្រួសារ

951

សេវាជួសជុលផ្សេងទៀត

952

សេវាបោកគក់ សំអាត ជ្រលក់ពណ៌

953

សេវាតាមគេហដ្ឋាន

959

សេវាបុគ្គលផ្សេងទៀត

96

960

អង្គការអន្តរជាតិផ្សេងៗ

## ផ្នែកទី០ : សកម្មភាពដទៃទៀត

00

000

សកម្មភាពដទៃទៀត

## សម្គាល់ :

[១] ការបែងចែកនេះ រួមមាន ជំពូក (លេខមួយខ្ទង់) ផ្នែក (លេខពីរខ្ទង់) ថ្នាក់ (លេខបីខ្ទង់) និង ក្រុម (លេខបួនខ្ទង់)។ក្រុមដែលមានបួនខ្ទង់មិនបានបង្ហាញនៅក្នុងឧសម្ព័ន្ធនេះទេ។ សម្រាប់ពត៌មានពិស្តារ សូមអានរបាយការណ៍ស្ថិតិរបស់អង្គការសហប្រជាជាតិ United Nations: *Statistical Papers*, Series M, No. 4, rev. 2 (New York, 1968).

# ឧបសម្ព័ន្ធទី ៣ :

# មូលដ្ឋានទិន្នន័យថ្នាក់ភូមិ និង ឃុំ-សង្កាត់ ឆ្នាំ ២០០៦

# មូលដ្ឋានទិន្នន័យថ្នាក់ភូមិ និង ឃុំ-សង្កាត់

(អតីត កម្មវិធីសីលា)

| | សំណួរ | 317 | 318 | 319 | 320 | 321 | 322 | 323 | 324 | 325 | 326 | 327 | 328 | 329 | 330 | 331 | 332 | 333 | 334 | 335 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
